**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៦៧ ស.ជ.ណ

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ផ្ញើជូន "វេទិកានិពន្ធនាយកសារព័ត៌មានកម្ពុជា"

## នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៧

*លោកនិពន្ធនាយកទាំងអស់ជាទីរាប់អាន*

ថ្ងៃនេះ តាងនាមឲ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង និងសូមចូលរួមអបអរសាទរវេទិកានិពន្ធនាយកសារព័ត៌មានកម្ពុជា ដែលបានរៀបចំឡើងជារៀងរាល់ឆ្នាំដោយក្លិបអ្នកកាសែតកម្ពុជា ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយ និងរៀបចំយន្តការសម្រាប់អនុវត្តក្នុងគោលបំណងលើកស្ទួយសិទ្ធិ សេរីភាពខាងសារព័ត៌មាន ពង្រឹងគុណភាព និងការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈសារព័ត៌មាន ដើម្បីចូលរួមចំណែកក្នុងការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ កសាងសុខសន្តិភាព ស្ថិរភាពនយោបាយ និងជំរុញការអភិវឌ្ឍប្រទេសកម្ពុជា ប្រកបដោយចីរភាព។

វេទិកានិពន្ធនាយកអ្នកសារព័ត៌មានកម្ពុជា ឆ្នាំ២០១៧ បានលើកយកប្រធានបទស្តីពី "សេរីភាព និងជំរុញការអភិវឌ្ឍ" គឺពិតជាមានសារសំខាន់ស្របតាមស្ថានភាពជាក់ស្តែងនិងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹង និងលើកស្ទួយសេរីភាពខាងសារព័ត៌មាន ក្នុងក្របខណ្ឌច្បាប់ដែលធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីរបបសារព័ត៌មាន និងជំរុញការចូលរួមរបស់សារព័ត៌មានក្នុងការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព នោះគឺជាបំណងប្រាថ្នា និងជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគោរព លើកកម្ពស់យ៉ាងហ្មត់ចត់នូវសេរីភាពសារព័ត៌មាន និងការកសាងព័ត៌មានប្រកបដោយវិជ្ជាជីវៈដើម្បីសម្រេចបាននូវការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និងការកសាងប្រទេសកម្ពុជា ប្រកបដោយសុខសន្តិភាព និងការអភិវឌ្ឍយ៉ាងពិតប្រាកដ។

*អស់លោកអ្នកសារព័ត៌មានទាំងអស់ជាទីស្រឡាញ់*

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះអ្នកសារព័ត៌មានទាំងអស់ដែលបានខិតខំបំពេញការងាររបស់ខ្លួនយ៉ាងសកម្មនិងពុះពាររាល់ការលំបាកដើម្បីយកព័ត៌មានផ្សព្វផ្សាយជូនសាធារណជនឲ្យបានដឹង និងស្វែងយល់អំពីការវិវត្តន៍ទាំងនៅក្នុងប្រទេស និងនៅលើសកលលោក។ បេសកកម្មរបស់អស់លោក ពិតជាបានចូលរួមចំណែកក្នុងការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និង

ការអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចំរើន ហើយរាជរដ្ឋាភិបាលកម្ពុជា តែងតែចាត់ទុកសារព័ត៌មាន គឺជាដៃគូអភិវឌ្ឍមិនអាចខ្វះបាន និងបានយកចិត្តទុកដាក់លើកស្ទួយវិស័យសារព័ត៌មានឲ្យមានការរីកចំរើនដូចវិស័យជាអាទិភាពចម្បងដទៃទៀតដែរ។

ការបើកទូលាយសេរីភាពសារព័ត៌មាននៅកម្ពុជា បានធ្វើឲ្យវិស័យនេះមានការរីកចំរើនយ៉ាងឆាប់រហ័សដែលរហូតមកដល់បច្ចុប្បន្ន មានអង្គភាពសារព័ត៌មានជាតិ និងអង្គភាពសារព័ត៌មានបរទេសដែលកំពុងធ្វើការផ្សព្វផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានចំនួន៥៣០អង្គភាព ក្នុងនោះកាសែតផ្សាយជាភាសាខ្មែរមានចំនួន១៣៩អង្គភាព កាសែតផ្សាយជាភាសាបរទេសមានចំនួន៤៣អង្គភាព ទស្សនាវដ្តីមានចំនួន៣០៦អង្គភាព ព្រឹត្តិបត្រព័ត៌មានចំនួន៤២អង្គភាព។ ចំណែកវិទ្យុមានចំនួន២១១ស្ថានីយ ក្នុងនោះវិទ្យុបរទេសមានចំនួន១០ស្ថានីយ ទូរទស្សន៍ផ្សាយផ្ទាល់មានចំនួន២១ស្ថានីយ និងទូរទស្សន៍ផ្សាយបន្តមានចំនួន១១២ស្ថានីយ ទូរទស្សន៍ផ្កាយរណបមានចំនួន០១ស្ថានីយ ទូរទស្សន៍ឌីជីថល (Pay-TV) មានចំនួន០៥ស្ថានីយ ទូរទស្សន៍អនឡាញមានចំនួន៥៨អង្គភាព និងការិយាល័យតំណាងទីភ្នាក់ងារសារព័ត៌មានបរទេស ការិយាល័យតំណាងវិទ្យុ-ទូរទស្សន៍បរទេសប្រចាំការអចិន្ត្រៃយ៍មានចំនួន២១អង្គភាព។

សមិទ្ធផលការរីកចម្រើននៃប្រព័ន្ធផ្សព្វផ្សាយតាមបែបបុរាណ និងតាមបច្ចេកវិទ្យាទំនើបនាពេលបច្ចុប្បន្នបានឆ្លុះបញ្ចាំងអំពីការរីកចម្រើន ការបើកទូលាយនូវសេរីភាពសារព័ត៌មាន និងការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជា លើវិស័យសារព័ត៌មាន ហើយបានប្រែក្លាយប្រទេសកម្ពុជា ទៅជាប្រទេសដែលមានសេរីភាពសារព័ត៌មានល្អជាងប្រទេសជាច្រើននៅតំបន់អាស៊ាន ដោយផ្អែកលើចំណុចសំខាន់ពីរគឺសេរីភាពនៃការបោះពុម្ពផ្សាយដោយគ្មានការត្រួតពិនិត្យជាមុន និងផ្តល់សិទ្ធិឲ្យជនបរទេសធ្វើជាម្ចាស់ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលនៅលើពិភពលោក កម្រមានប្រទេសណាមួយអនុញ្ញាតឲ្យជនបរទេសកាន់កាប់ធ្វើជាម្ចាស់ប្រព័ន្ធផ្សព្វផ្សាយបែបនេះណាស់។

យើងក៏ត្រូវមើលឃើញផងដែរថា សារព័ត៌មានពិតជាអាវុធមុខពីរ ប្រសិនបើការប្រើសេរីភាពប្រកបដោយវិជ្ជាជីវៈ និងក្នុងក្របខណ្ឌច្បាប់ សារព័ត៌មានពិតជាបានចូលរួមចំណែកក្នុងការជួយលើកស្ទួយលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស ការកសាងសន្តិភាព ស្ថិរភាពនយោបាយនិងការអភិវឌ្ឍប្រទេសជាតិ ប៉ុន្តែប្រសិនបើការប្រើប្រាស់សេរីភាពហួសព្រំដែនដោយបំពានច្បាប់ សារព័ត៌មានពិតជាបានបំផ្លាញលទ្ធិប្រជាធិបតេយ្យ បំផ្លាញសុខសន្តិភាព និងការអភិវឌ្ឍជាតិ ហើយរុញច្រានឲ្យប្រទេសធ្លាក់ក្នុងភ្លើងសង្គ្រាមយ៉ាងពិតប្រាកដ។ រាជរដ្ឋាភិបាលកម្ពុជា នឹងមិនអនុញ្ញាតឲ្យមានការប្រើប្រាស់សេរីភាពតាមបែបអនាធិបតេយ្យដោយបំពានច្បាប់ ដើម្បីធ្វើបដិវត្តពណ៌ផ្តួលរំលំរាជរដ្ឋាភិបាលកម្ពុជាស្របច្បាប់ជាដាច់ខាត។

ជាថ្មីម្តងទៀត ខ្ញុំសូមអរគុណ និងសូមវាយតម្លៃខ្ពស់ចំពោះតួនាទីដ៏ចម្បងរបស់អ្នកសារព័ត៌មាន និងស្ថាប័នប្រព័ន្ធផ្សព្វផ្សាយមួយចំនួនធំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយព័ត៌មានប្រកបដោយវិជ្ជាជីវៈអំពីស្ថានភាពនយោបាយ ការអភិវឌ្ឍ និងសភាពការណ៍ពិតនៅកម្ពុជា ចាប់តាំងពីដំណាក់កាលប្រទេសជាតិមានសង្គ្រាម និងដំណាក់កាលស្វែងរកសន្តិភាព រហូតដល់ប្រទេសបានទទួលសុខសន្តិភាពពេញលេញ និងមានការអភិវឌ្ឍនាពេលបច្ចុប្បន្ន។

ការចូលរួមកសាងសុខសន្តិភាព អ្នកសារព័ត៌មានបានដើរតួនាទីជាអ្នកសម្របសម្រួលនយោបាយ។ នៅពេលប្រទេសកំពុងប្រឈមនឹងភាពតានតឹងនៃការធ្វើបដិវត្តពណ៌ប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលកម្ពុជា និងការគេចវេះការបំពេញកាតព្វកិច្ចអនុវត្តច្បាប់របស់អ្នកសារព័ត៌មានមួយចំនួនហើយបានបង្វែរសភាពការណ៍ទៅជាបញ្ហានយោបាយ ដើម្បីទម្លាក់កំហុសមកលើរាជរដ្ឋាភិបាល សារព័ត៌មានបានដើរតួនាទីជាអ្នកសម្របសម្រួលតាមរយៈការសរសេរអត្ថបទរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវវិជ្ជាជីវៈ និងមានការទទួលខុសត្រូវខ្ពស់ មិនបំប៉ោងព័ត៌មានដែលធ្វើឲ្យសភាពការណ៍នយោបាយឡើងកំដៅ។ ទាំងនេះ គឺបានឆ្លុះបញ្ចាំងពីតួនាទីដ៏សំខាន់របស់សារព័ត៌មានក្នុងការចូលរួមកសាងសន្តិភាព ស្ថិរភាពនយោបាយ ការអភិវឌ្ឍប្រទេសជាតិដោយការផ្តល់ព័ត៌មានប្រកបដោយការជឿទុកចិត្ត និងការទទួលខុសត្រូវទៅលើអាជីពរបស់ខ្លួន ហើយរាជរដ្ឋាភិបាលកម្ពុជា នៅតែប្រកាន់ជំហរនិងប្តេជ្ញាចិត្តខ្ពស់ក្នុងការលើកស្ទួយសេរីភាពសារព័ត៌មាននៅកម្ពុជា ដោយចាត់ទុកសារព័ត៌មានគឺជាដៃគូសំខាន់ក្នុងការជំរុញការអភិវឌ្ឍប្រទេសប្រកបដោយ តម្លាភាព និរន្តរភាព និងការទទួលខុសត្រូវ។

មុននឹងបញ្ចប់ ខ្ញុំសូមលើកទឹកចិត្តនិងអំពាវនាវដល់បងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលកំពុងបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមយកចិត្តទុកដាក់អនុវត្តឲ្យបានត្រឹមត្រូវតាមក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មាន គោរពច្បាប់ ជៀសវាងការស្វែងរកប្រយោជន៍ផ្ទាល់ខ្លួនធ្វើការផ្សព្វផ្សាយព័ត៌មានតែមួយជ្រុង ហើយឆ្លុះបញ្ចាំងសភាពការណ៍ទាំងមូលដោយពុំបានគិតគូរអំពីក្បួនខ្នាត ក្រឹត្យក្រមនៃការសរសេរព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មានមិនពិត បំប៉ោងសភាពការណ៍រុញច្រានប្រទេសឲ្យធ្លាក់ក្នុងភាពវឹកវរ អស្ថិរភាពនយោបាយ បង្កឲ្យកើតមានជម្លោះប្រដាប់អាវុធជាមួយប្រទេសជិតខាង និងធ្វើឲ្យសង្គមកើតចលាចលឈានទៅរកការផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ តាមរយៈចលនាបដិវត្តពណ៌ដែលជាអំពើខុសច្បាប់ មិនអាចអត់អោនឲ្យបានឡើយ។

ទីបញ្ចប់ ខ្ញុំសូមកោតសរសើរដល់ក្លិបអ្នកកាសែតកម្ពុជា ដែលបានរៀបចំវេទិកានេះឡើងក្នុងគោលដៅពង្រឹងវិជ្ជាជីវៈអ្នកសារព័ត៌មាននៅកម្ពុជា ដើម្បីទទួលបានជោគជ័យក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន និងសូមជូនពរបងប្អូនអ្នកសារព័ត៌មានទាំងអស់ និងបងប្អូនប្រជាពលរដ្ឋនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ជួបប្រទះតែនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**